**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៥ អនក្រ.សរ**

[illegible]

# សេចក្តីសំរេច

## ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីចុះពិនិត្យទីតាំងសិក្សាស្រាវជ្រាវរ៉ែត្បូង នៅតំបន់ភ្នំត្រប់ ក្រុងប៉ៃលិន របស់ក្រុមហ៊ុន SONUBA CHAM INDUSTRIES CO.,LTD.

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣
- យោងអនុក្រឹត្យលេខ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងស្មារតីអង្គប្រជុំ"ច្រកចេញ-ចូលតែមួយ" នៃ ក.អ.ក"គ.វ.ក" នាថ្ងៃទី១៥ និងទី១៩ ខែកុម្ភៈ ឆ្នាំ២០០៧ និងចំណារសម្តេចនាយករដ្ឋមន្ត្រី ប្រធាន"ក.អ.ក" ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៧

## សំរេច

**ប្រការ១:** បង្កើតក្រុមការអន្តរក្រសួង ដើម្បីចុះពិនិត្យទីតាំងសិក្សាស្រាវជ្រាវរ៉ែត្បូង នៅតំបន់ភ្នំត្រប់ ក្រុងប៉ៃលិន របស់ក្រុមហ៊ុន SONUBA CHAM INDUSTRIES CO.,LTD. ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម ម៉ុក មារ៉េត | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន | ប្រធាន |
| ២- ឯកឧត្តម ស៊ុយ សែម | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | អនុប្រធាន |
| ៣- ឯកឧត្តម នុត ណារ៉ុង | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៤- ឯកឧត្តម សួន សិទ្ធី | អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា | សមាជិក |
| ៥- ឯកឧត្តម ហ៊ីង ថូរ៉ាក់ស៊ី | ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦- ឯកឧត្តម អ៊ឹង ប៊ុណ្ណារ៉ា | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៧- ឯកឧត្តម មួង សៅខន | អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៨- ឯកឧត្តម ស្រ៊ុន តារា | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៩- ឯកឧត្តម សុខ ឡេង | អគ្គនាយក នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១០- ឯកឧត្តម អ៊ិច សារូ | អភិបាលរងក្រុងប៉ៃលិន | សមាជិក |
| ១១- លោក គិត សេង | ប្រធាននាយកដ្ឋាននៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១២- លោកស្រី ជូ ស៊ុជាន់នី | ប្រធាននាយកដ្ឋាននៃក្រសួងបរិស្ថាន | សមាជិក |
| ១៣- លោក ឆេង គីមស៊ុន | នាយករងរដ្ឋបាលព្រៃឈើ | សមាជិក |
| ១៤- លោក យ៉ុន ហេង | អនុប្រធាននាយកដ្ឋាន នៃ គ.អ.ក ត.វ.ក | លេខាធិការ |

សមាជិកក្រុមការងារទាំងអស់ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន ក្នុងករណីប្រធានអវត្តមាន ។

**ប្រការ២:** ក្រុមការងារអន្តរក្រសួងនេះ មានភារកិច្ចដូចតទៅ :

- ចុះពិនិត្យសិក្សាវាយតំលៃលើស្ថានភាពប៉ះពាល់បរិស្ថាននៅតំបន់ភ្នំត្រប់ ដែលបណ្តាលមកពីសកម្មភាពសិក្សាស្រាវជ្រាវរបស់ក្រុមហ៊ុន SONUBA CHAM INDUSTRIES CO.,LTD. ។
- ពិនិត្យវាយតំលៃពីគុណសម្បត្តិ និងគុណវិបត្តិ ក្នុងករណីផ្តល់គោលការណ៍អោយក្រុមហ៊ុន SONUBA CHAM INDUSTRIES CO.,LTD. ធ្វើការសិក្សាស្រាវជ្រាវបន្ត។
- ពិនិត្យសិក្សាលើផ្នែកពាក់ព័ន្ធគ្រប់ជ្រុងជ្រោយ សំដៅធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលពិនិត្យសំរេចលើករណីសំណើសុំបន្តការសិក្សាស្រាវជ្រាវរ៉ែត្បូង នៅតំបន់ភ្នំត្រប់ ក្រុងប៉ៃលិន របស់ក្រុមហ៊ុន SONUBA CHAM INDUSTRIES CO.,LTD. ។

**ប្រការ៣:** គ្រប់សមាសភាពនៃក្រុមការងារអន្តរក្រសួង មានសិទ្ធិនាំយកទៅជាមួយនូវមន្ត្រីបច្ចេកទេសជំនាញ ដោយគ្រាន់តែមានលិខិតឧទ្ទេសនាមពីប្រធានស្ថាប័នរបស់ខ្លួនបន្ថែមប៉ុណ្ណោះ នៅពេលចុះបំពេញបេសកកម្ម។

**ប្រការ៤:** ក្រុមការងារអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ត្រា និងកញ្ចប់ថវិការបស់ក្រុមប្រឹក្សាភិវឌ្ឍន៍កម្ពុជា សំរាប់អនុវត្តការងារ ។

**ប្រការ៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់-រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម-រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ-ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា-រដ្ឋមន្ត្រីគ្រប់ក្រសួង-គ្រប់ប្រធានស្ថាប័ន-សាលាក្រុងប៉ៃលិន និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀង១ខ្លួន អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ប្រធាន "ក.អ.ក"
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ